Reading Book

# ពិភពរឿងនិទាន
The World of Stories

# បុត្រីនាគ
## Dragon's Daughter



សៀវភៅជាឃ្លាំងនៃចំណេះដឹង

*Books are the source of knowledge*

កាលពីព្រេងនាយ មានយុវជនម្នាក់ឈ្មោះ **វិបុត្រ** ជាអ្នកនេសាទត្រី រស់នៅក្បែរសមុទ្រ។ រាល់ថ្ងៃគាត់តែងតែជិះទូកទៅនេសាទត្រីដើម្បីចាប់ត្រីមកលក់គ្រាន់បានកម្រៃខ្លះៗមកដោះស្រាយជីវភាពគ្រួសារ។ នៅល្ងាចថ្ងៃមួយ គាត់បានចេញទៅនេសាទដូចសព្វដង។



ពេលនោះ   គាត់បានជួបនឹងក្មេងៗមួយក្រុមកំពុងសើចយ៉ាងខ្ញៀវខ្ញា ដោយនាំគ្នាយួរកន្ទុយអណ្ដើកតូចមួយយោលទៅយោលមក និងមានកាន់រំពាត់គោះវាយស្នូកអណ្ដើកធ្វើជាចង្វាក់ភ្លេង។

Once upon a time, there was a fisherman named **Vibot** living near the sea. Every day, **Vibot** went fishing by a boat to earn income for supporting his family. One evening, when he went to fish as usual, he saw a group of children playing so happily. Those children were carrying the tail of a small turtle and swinging it, and they were also beating the shell of that turtle with a small stick to make music.



**វិបុត្រ** រំជួលចិត្តអាណិតកូនអណ្ដើកជាខ្លាំង ក៏សុំឱ្យពួកគេដោះលែងកូនអណ្ដើកនោះ។ កុមារទាំងអស់សោកស្ដាយនូវភាពរីករាយ តែក៏ព្រមប្រគល់កូនអណ្ដើកឱ្យទៅ **វិបុត្រ** ដែរ។ ពេលនោះ **វិបុត្រ** សម្លឹងមើលកូនអណ្ដើកដោយយកចិត្តទុកដាក់។ គាត់មានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះស្នូករបស់វាបញ្ចេញពណ៌ភ្លឺផ្លេកៗខុសប្លែកពីអណ្ដើកដទៃទៀត។ នៅទីបំផុត គាត់ដាក់វាចុះនៅក្បែរមាត់ទឹក។ ពេលនោះ កូនអណ្ដើកស្ទុះវារយ៉ាងលឿនសំដៅទៅរកទឹករលក។ **វិបុត្រ** ឃើញកូនអណ្ដើកងើបឡើងហើយងក់ក្បាលដាក់ **វិបុត្រ** ជាសញ្ញាអរគុណ។



With compassion for the small turtle, **Vibot** gently asked those children to release it. When hearing this, the children felt so sorry that their excitement was stopped; however, they agreed to hand over the small turtle to **Vibot**. While holding the small turtle in hand, **Vibot** looked at it carefully. He was so surprised as he saw the shell of the turtle came radiant which was different from others. Then, the fisherman laid the turtle down next to the edge of sea. The small turtle bent the head down to express a great thank to **Vibot** and hurriedly crept into the water.



នៅថ្ងៃបន្ទាប់ **វិបុត្រ** បានចេញទៅនេសាទត្រីទៀត គាត់និយាយតិចៗតែម្នាក់ឯងថា "សូមឱ្យខ្ញុំមានសំណាងល្អក្នុងថ្ងៃនេះ!" ហើយគាត់ក៏រាយមងទៅក្នុងទឹក។ រំពេចនោះ មានអណ្ដើកធំមួយបានងើបឡើងក្បែរគែមទូកឱនក្បាលគោរពអ្នកនេសាទហើយនិយាយថា "សួស្ដីអ្នកកំលោះ! ខ្ញុំមកដើម្បីអរគុណអ្នកដែលបានជួយសង្គ្រោះជីវិតកូនអណ្ដើកតូចកាលពីម្សិលមិញ។ ម្យ៉ាងទៀត ស្ដេចនាគជាម្ចាស់របស់ខ្ញុំ ទ្រង់បានបញ្ជាខ្ញុំឱ្យមកទទួលអ្នកទៅរាជវាំង ពីព្រោះព្រះអង្គចង់អរគុណអ្នកដោយផ្ទាល់ សូមលោកជិះលើខ្នងខ្ញុំមក!" **វិបុត្រ** ភ្ញាក់ផ្អើលហើយរំភើបចិត្តក៏យល់ព្រមចុះពីទូកទៅជិះលើខ្នងអណ្ដើកនោះភ្លាម។ អណ្ដើកបានបង្វិលខ្លួនយឺតៗហើយហែលនាំ **វិបុត្រ** ជ្រែកទឹកសមុទ្រមិនបង្អង់។ ក្នុងពេលធ្វើដំណើរ **វិបុត្រ** បានឃើញត្រីគ្រប់ពណ៌ និងរុក្ខជាតិសមុទ្រចំលែកៗនៅជុំវិញខ្លួន។



Next day, when **Vibot** went fishing, he prayed in a low voice, "May I have a good luck today!" After praying, he started to set the net. Suddenly, there appeared a huge turtle from the surface of the sea near his boat and bowed the head to show a respect to the fisherman and said, "Hi gentleman, I'm here to say thank to you for helping to rescue a small turtle yesterday; moreover, my master, the King of Dragon, ordered me to come and invite you to the Royal Palace in order that he can express his gratitude to you by himself. Please come and ride on my back and I'll bring you there." **Vibot**, in such a moment, was so surprised together with excitement and he made a quick decision to leave his boat and got onto the back of the turtle. Then, the turtle slowly turned to the right direction and swam right away. A long the journey to the Royal Palace, **Vibot** saw many kinds of fishes with different colors and strange sea plants along.





បន្តិចក្រោយមក ពួកគេបានមកដល់ដីក្រោមសមុទ្រដែលមានភ្នំធំៗ និងជ្រលងរាក់ជ្រៅជាច្រើនកន្លែង។ នៅពីមុខជួរភ្នំ គេឃើញរាជវាំងមួយ មានកំផែងភ្លឺផ្លេកៗគឺជារាជវាំងរបស់ស្តេចនាគ ប្រាសាទមានជញ្ជាំងលំអរ



ទៅដោយផ្កាថ្មផ្សេងៗ និងដំបូលរចនាទៅដោយសំបកខ្យងសំបកខ្ចៅសមុទ្រល្អៗគ្រប់ប្រភេទ ដែលភ្លឺចែងចាំងនៅក្នុងទឹកគួរឱ្យចង់គយគន់។ នាយ **វិបុត្រ** បានជួបវត្ថុចម្លែកដែលគេមិនធ្លាប់ឃើញ។ ទីបំផុត គេបានទៅដល់ដំណាក់រាជបល្ល័ង្ករបស់ស្តេចនាគ។ នៅទីនោះ ស្តេចនាគបានគង់នៅចំពីមុខ **វិបុត្រ**។ **វិបុត្រ** ក៏លុតជង្គង់ឱនគោរពព្រះអង្គ។ ស្តេចនាគមានព្រះបន្ទូលដោយសុភាពថា "យើងឱ្យគេនាំអ្នកមកកាន់ទីនេះ គឺចង់អរគុណអ្នកដោយផ្ទាល់អំពីការជួយជីវិតបុត្រីរបស់យើង"។

A moment later, they arrived at the underground of the sea where there were a lot of big mountains with deep and sallow valleys. In front of the mountain range, **Vibot** saw a radiant wall of a glittering royal palace of the Dragon King. The wall of this castle was decorated with different kinds of coral and the roof was embellished with various beautiful shells which made it an attractively radiant glow under the water. **Vibot** saw many marvelous things he had never seen before. In the end, he reached the throne of the Dragon King. The Dragon King was sitting in front of him and **Vibot** kneeled down to respect the King. The Dragon King said gently, "I've ordered someone to bring you here because I'd like to express my own thank to you for helping my daughter."

បន្តិចក្រោយមក ព្រះនាងក៏យាងមកដល់ស្រដីថា "ខ្ញុំជាកូនអណ្តើកតូចដែលអ្នកបានជួយជីវិតខ្ញុំពីពួកកុមារ"។ **វិចុត្រ** ឈរភ្លឹករកនិយាយស្តីអ្វីមិនកើតនូវព្រះភក្ត្រដ៏ផូរផង់ និងដំណើរល្វតល្វន់ដូចស្មៅសមុទ្រដែលរេទៅរេមកតាមចលនាទឹក។ ស្នាមញញឹមស្រស់ស្រទន់ដូចរលកសមុទ្រនាពេលស្ងប់ខ្យល់។ ព្រះនាងបានបញ្ជាក់ថា "ខ្ញុំមិនដែលចេញពីព្រះរាជវាំងនេះទេ។ តែខ្ញុំចង់ឃើញប្រជាជនដែលរស់នៅលើផែនដី ខ្ញុំក៏បានក្លែងខ្លួនជាកូនអណ្តើកតូចមួយ ហើយហែលទៅមាត់សមុទ្រក្បែរភូមិរបស់អ្នក។ ប៉ុន្តែនៅពេលខ្ញុំកំពុងវារកាត់ឆ្នេរខ្សាច់ ក៏ត្រូវក្រុមកុមារទាំងនោះចាប់ធ្វើជាល្បែងលេង។ ប្រសិនបើអ្នកមិនជួយខ្ញុំទេ ខ្ញុំប្រហែលជាបាត់បង់ជីវិតក្នុងពេលនោះបាត់ទៅហើយ"។



Soon afterward, the Princess of the Dragon King came and said, "I am a small turtle which you have rescued me from the children." **Vibot** could not speak out because he was so much attracted by her beautiful face and gentle walk like the seaweed swinging through the move of the seawater. Her smile was so nice and fresh like the waves of the sea. The Princess claimed that "I have never left the Royal Palace. But I want to see the people on earth, I metamorphosed into a small turtle and swam to the sea sore near the village. But when I was crawling on the sand, I was caught by the children. If you had not helped me, I would have died in that time."



ព្រះនាងបានបន្តទៀតថា "ខ្ញុំភ្លេចគិត! អ្នកពិតជាឃ្លានណាស់ហើយ ព្រោះធ្វើដំណើរវែងឆ្ងាយណាស់!" ព្រះនាងក៏លើកដៃបក់ ពេលនោះនៅលើតុ ក៏មានអាហារឈ្ងុយឆ្ងាញ់ត្រៀបត្រាបានផុសឡើង។ ចានស្លាបព្រាសម សុទ្ធតែធ្វើអំពីមាសនិងប្រាក់ល្អៗ ម្ហូបមានឱជារសឈ្ងុយឆ្ងាញ់។ ព្រះនាងក៏លើកដៃបក់ម្តងទៀត។ រំពេចនោះ សម្លេងជូរ្យតន្ត្រីដ៏ពីរោះរងំបានបន្លឺឡើងកំដរនៅពេលបរិភោគអាហារ។ បន្ទាប់ពីស្រស់ស្រូបអាហាររួច ព្រះនាងនាំ **វិបុត្រ** ទៅទស្សនាក្នុងវិមានដ៏ល្អអស្ចារ្យ។ បន្តិចក្រោយមក អ្នកទាំងពីរបានមកដល់បង្អួចធំមួយឈរសម្លឹងមើលវាលស្រែដែលកសិករកំពុងស្ទូងស្រូវនៅរដូវផ្ការីក។



ប៉ុន្តែ **វិបុត្រ** សង្កេតឃើញថាសន្ទូងទាំងអស់នោះលូតលាស់ភ្លាមៗ មួយរំពេច។ ទេសភាពប្តូរពណ៌ស្រស់ថ្លានៅរដូវផ្ការីកទៅជាស្រអាប់យ៉ាង ឆាប់រហ័សនារដូវភ្លៀងធ្លាក់។

She added that "I absolutely forget; you may be very hungry because you have been traveling very far!" Princes waved her hand, the table with plenty of tasty food came up. Plats, spoons and forks were all made of gold and silver. Then she waved again, suddenly the sound of music came as an entertainment during the meal. After the meal, the Princes guided **Vibot** to visit the wonderful castle and then they both arrived at a large window and glanced to the rice field that the farmers were transplanting rice seedling during the spring. But **Vibot** observed that the rice seedling grew up rapidly. The view changed rapidly from bright color in spring to the dark color in rainy season.





**វិបុត្រ** ឆ្ងល់ខ្លាំងជាងគេ គឺនៅពេលដែលឃើញដើមស្រូវឱនចុះដោយសារក្ដួរគ្រាប់ដ៏ធ្ងន់របស់វាបន្ទាប់ពីស្ទូងរួចភ្លាមៗក្នុងថិរវេលាយ៉ាងខ្លី រដូវកាលទាំង៤បានកើតឡើង ហើយបញ្ចប់ទៅវិញភ្លាមៗនៅចំពោះមុខ។ ពេលវេលាចេះតែកន្លងទៅ **វិបុត្រ** រស់នៅក្នុងព្រះរាជវាំងក្រោមសមុទ្រប្រកបដោយភាពស្រស់ថ្លាក្រៃលែង។ ព្រះរាជបុត្រីបានទទួល **វិបុត្រ** ជាស្វាមីដោយភក្ដីស្មោះស្ម័គ្រ។ អ្នកបម្រើទាំងឡាយបានបំពេញគ្រប់បំណងប្រាថ្នារបស់ **វិបុត្រ**។ **វិបុត្រ** បានសួរខ្លួនឯងថា តើជាការពិត ឬក៏ជាសុបិន?។

What made **Vibot** wonder so much was the rice stalk that bent down soon after transplanting. In short period of time, four seasons have gone through and ended suddenly. The times have consequently passed; **Vibot** lived in the Royal Palace under the sea with the wonderful life. The Princess honestly accepted **Vibot** as her husband. All servants served all needs of **Vibot**. Vibot asked himself that it was true or it was just only a dream.



ប៉ុន្តែថ្ងៃមួយស្រាប់តែ **វិបុត្រ** នឹកទៅដល់ទូកនេសាទ និងការលើកមងដែលមានត្រីជាប់រណែងរណោងចេញពីទឹកសមុទ្រ។ ភ្លាមនោះគាត់ក៏នឹកឃើញអ្នកម្ដាយកំសត់ និងញាតិមិត្តក្នុងភូមិ។ ពេលនោះ គាត់អន្ទះសាជាខ្លាំង។



ណាមួយចង់ឃើញអ្នកទាំងអស់នោះផង ណាមួយជំពាក់ចិត្តយ៉ាងខ្លាំងនឹងការរស់នៅក្នុងព្រះរាជវាំងនេះផង។ ដោយទ្រាំពុំបាន គាត់ក៏សម្រេចចិត្តសុំព្រះនាងទៅសួរសុខទុក្ខក្រុមគ្រួសាររបស់គាត់។ ព្រះនាងក៏យល់ព្រមទាំងព្រួយបារម្ភ ហើយប្រគល់ប្រអប់ពណ៌មាសដ៏ល្អមួយវាចាថា "សូមម្ចាស់បងកុំបើកមើលវត្ថុខាងក្នុងនេះអី ដរាបណាប្រអប់នេះនៅល្អម្ចាស់បងនឹងបានមកជួបខ្ញុំម្ចាស់វិញ"។ **វិបុត្រ** កាន់ដៃព្រះនាងយ៉ាងណែនហើយសន្យាថា "បងមិនបើកប្រអប់នេះជាដាច់ខាត បងនឹងត្រលប់មករកអូនក្នុងពេលឆាប់ៗនេះ"។ ក្រោយពីគោរពលាព្រះបិតាក្មេករួច គាត់ក៏ចាកចេញពីព្រះរាជវាំងនោះភ្លាម។

One day, however; **Vibot** remembered his fishing boat and the time he collected the fishing net with a lot of fishes trapped. Suddenly, he remembered his poor mother and other relatives in the village that made him feel anxiously at that time. He anxiously wanted to see those people, but he was also interested in his life living in the palace. Because of the strong feeling of anxiety, he decided to ask the Princess to visit his family. The Princess reluctantly agreed and provided a golden-colored box to him with the message "Please don't open this box, as soon as this box is in good condition, you will meet me again." **Vibot** tightly held the Princess's hands and promised that "I will never open it and I will be back to meet you soon." After showing respect to this farther-in-law, he left the palace immediately.





**វិបុត្រ** ជិះលើខ្នងអណ្ដើកធំម្ដងទៀត។ គាត់ធ្វើដំណើរឆ្ពោះទៅភូមិកំណើតរបស់គាត់។ ពេលចេញផុតពីកំផែងព្រះរាជវាំង គាត់បានឆ្លងកាត់ជ្រលង និងល្អាងថ្មតូចធំជាច្រើន ហើយក៏បានមកដល់លើផ្ទៃទឹកសមុទ្រ។ ពេលនោះ គាត់បានមើលឃើញផ្ទះក្នុងភូមិរបស់គាត់ឡើងវិញ។ គាត់អរគុណអណ្ដើកធំ ហើយរត់យ៉ាងលឿនកាត់ឆ្នេរខ្សាច់សំដៅទៅភូមិរបស់គាត់។ ប៉ុន្តែអ្វីៗបានប្រែប្រួលអស់ទៅហើយមានតែជួរភ្នំក្រោយភូមិប៉ុណ្ណោះដែលបិតនៅដដែល។ ចំណែកផ្លូវ និងផ្ទះបានផ្លាស់ប្ដូរទាំងអស់។ គាត់ដើរតាមផ្លូវមួយសំដៅទៅផ្ទះរបស់គាត់។ ប៉ុន្តែទីនោះ គ្មានផ្ទះរបស់គាត់ទៀតទេ មានតែផ្ទះមួយផ្សេងទៀតដែលគាត់មិនដែលឃើញពីមុនមក។



**Vibot** got onto the back of the big turtle again then the turtle brought him to his homeland. After he got out of the wall of the royal palace, he had to go across many small and big valleys and caverns until he appeared on the surface of the sea. While appearing on the surface of the sea, he could see the roof of his home in his village. When he reached the beach, he expressed his great thank to the big turtle and he ran so fast across the beach towards his village. But when he arrived in his village, he saw everything had changed except the range of mountain lying behind his home. All streets and homes in the village had changed. He went straight away a long the street to his home, but he didn't see it at all. He only saw a home that he had never known before.



**វិបុត្រ** បានសួរអ្នកភូមិម្នាក់ថា "តើកន្លែងនេះជាកន្លែងដែល **វិបុត្រ** ធ្លាប់រស់នៅពីមុនមកមែនទេ?" អ្នកភូមិបានសម្លឹងមើលគាត់ដោយឆ្ងល់ និងចម្លែកក្នុងចិត្ត "ផ្ទះរបស់គាត់ទ្រុឌទ្រោមបាក់បែកជាយូរឆ្នាំមកហើយ។ កាលពីកុមារ ខ្ញុំបានស្តាប់ជីតាខ្ញុំនិទានរឿងមួយដែលគាត់និយាយពីតាលួត របស់ខ្ញុំ។ រឿងនេះមានសេចក្តីថា "ព្រឹកមួយ **វិបុត្រ** ចេញទៅនេសាទត្រី ដូចធម្មតា។ ប៉ុន្តែគេមិនឃើញគាត់ត្រលប់មកផ្ទះវិញទេ គេឃើញតែទូក របស់គាត់ប៉ុណ្ណោះ គ្មាននរណាម្នាក់ដឹងពីការបាត់ខ្លួនរបស់គាត់ឡើយ អ្នកភូមិទាំងអស់ស្មានថា គាត់ត្រូវសត្វសមុទ្រកំណាចចាប់បាត់ទៅហើយ" ស្តាប់រឿងចប់ **វិបុត្រ** អរគុណអ្នកភូមិហើយដើរសំដៅទៅមាត់សមុទ្រវិញ។

**Vibot** asked a villager, "Is it the place where **Vibot** used to live in before?" That villager looked at him doubtfully and surprisingly, then replied, "His home had become old and collapsed so long time ago. When I was young, I used to listen to my grandfather narrating a story of my great grandfather. He narrated that in one morning **Vibot** went to fish as usual. Since he had left his home, he was not seen coming back home. Only his boat was seen and no one knew the cause of his disappearance. All villagers assumed that he might be caught by vicious sea creatures." After listening to the story till the end, **Vibot** thanked the villager and went to the beach.





គាត់គិតថា តើគាត់រស់នៅក្នុងព្រះរាជវាំងក្រោមសមុទ្រអស់រយៈពេលប៉ុន្មានឆ្នាំហើយ? ហេតុអ្វីក៏គាត់ឋិតនៅក្នុងវ័យក្មេងដដែលដូច្នេះ? ភ្លាមនោះគាត់មានអារម្មណ៏ត្រមង់ត្រមោចសម្លឹងមើលប្រអប់ពណ៌មាស។ **វិបុត្រ** ភ្លេចអស់ពាក្យបណ្ដាំភរិយាគាត់ ក៏ស្រាយចំណងប្រអប់ហើយបើកគំរបថ្នមៗ។ ពេលនោះផ្សែងពណ៌សបានផុសឡើង។ **វិបុត្រ** ក៏ក្លាយខ្លួនជាតាចាស់សក់ស្កូវនិងចេញពុកចង្កាពណ៌សមួយរំពេច។

He asked himself, “How long had I lived in the royal palace under the sea? Why am I still young?” Meanwhile, he felt so lonely and he looked at the golden box that he brought with. As **Vibot** forgot his wife’s advice, he opened the cover of that box gently. Suddenly, the white smoke came out from the box and **Vibot** rapidly became a very old man with white hair and white beard.

ក្នុងខណៈពេលនោះ គាត់បានឮសម្លេងព្រះនាងចេញពីផ្ទៃសមុទ្រ "ព្រះស្វាមី ព្រះអង្គមិនអាចបើកប្រអប់នេះបានទេ ព្រោះក្នុងនេះខ្ញុំម្ចាស់បានថែរក្សាជីវិតទ្រង់ឱ្យនៅក្មេងជារៀងរហូត។ ប៉ុន្តែ... ខ្ញុំម្ចាស់សុំលាព្រះអង្គហើយ"។ បន្ទាប់ពីនោះមក លោកតា **វិបុត្រ** ឮសូរតែទឹករលកបោកឆ្នេរខ្សាច់ ក្បែរជើងរបស់គាត់តែប៉ុណ្ណោះ។

ចប់

## សន្យាជាបំណុល



At that moment, he heard a sound of the Princess coming out from the surface of the sea "My honey, you cannot open this box because I can help make you remain young forever. But.... I would like to say goodbye to you." After that, **Vibot**, who became an old person, only heard the sound of waves hitting the beach near his feet. **The End**

**(Promise is a debt.)**